# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ ៣៦២៧ ព.ណ.រ.ន.ជស

ថ្ងៃអង្គារ ១ រោច ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០២០

# សេចក្តីជូនដំណឹង
## ស្តីពី
## ថ្លៃលក់រាយប្រេងឥន្ធនៈនៅតាមស្ថានីយ

- យោងប្រកាសអន្តរក្រសួងលេខ១៧២ពណ. អវង.ប្រក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និងក្រសួងរ៉ែ និងថាមពល ស្តីពីការកំណត់រូបមន្តសម្រាប់កែសម្រួលថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជា
- យោងលើការព្រមព្រៀង លើរូបមន្តកំណត់តម្លៃជាមួយក្រុមហ៊ុនប្រេងឥន្ធនៈដែលប្រកបអាជីវកម្មនៅកម្ពុជា
- យោងការប្រែប្រួលនៃតម្លៃប្រេងឥន្ធនៈលើទីផ្សារក្នុងតំបន់ និងអន្តរជាតិ

ផ្អែកតាមតម្លៃមធ្យមប្រេងឥន្ធនៈលើទីផ្សារអន្តរជាតិ ថ្លៃលក់រាយប្រេងឥន្ធនៈពីថ្ងៃទី០១ ដល់ ១៥ ខែធ្នូ ឆ្នាំ២០២០ នឹងត្រូវលក់ ៣.១៧៤រៀល/១លីត្រ សម្រាប់សាំងធម្មតា EA92 និង ២.៩១២រៀល/លីត្រ សម្រាប់ប្រេងម៉ាស៊ូត។

ដើម្បីជួយសម្រួលដល់ជីវភាពរបស់ប្រជាជន និងដោយមានការរួមចំណែកពីក្រុមហ៊ុនចែកចាយប្រេងឥន្ធនៈនៅកម្ពុជា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានសម្រេចបញ្ចុះតម្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជា ចំនួន៤សេនដុល្លារ/លីត្រ ។

ដូច្នេះថ្លៃលក់រាយប្រេងឥន្ធនៈសម្រាប់អនុវត្ត **ចាប់ពីថ្ងៃទី០១ ដល់ ១៥ ខែធ្នូ ឆ្នាំ២០២០** នឹងចុះមក ៣.០០០ រៀល/លីត្រ សម្រាប់សាំងធម្មតា EA92 និង ២.៧៥០ រៀល/លីត្រ សម្រាប់ប្រេងម៉ាស៊ូត ។

ការគណនាថ្លៃលក់រាយប្រេងឥន្ធនៈមានលម្អិតដូចតារាងខាងក្រោម៖

**តារាងថ្លៃលក់រាយប្រេងឥន្ធនៈនៅលើទីផ្សារកម្ពុជា**

| ល.រ | អធិប្បាយ | ប្រេងសាំងធម្មតា/លីត្រ (Gasoline 92) | | ប្រេងម៉ាស៊ូត/លីត្រ (Gasoil) | |
|---|---|---|---|---|---|
| ១ | **Average MOPS** | | ០,២៩៧២ ដុល្លារ | | ០,៣១៥១ ដុល្លារ |
| ២ | ពន្ធ៖ | | ០,១៧៩១ ដុល្លារ | | ០,០៦៩៦ ដុល្លារ |
| | ពន្ធគយ | ០,០៧២៦ ដុល្លារ | | ០,០០០០ ដុល្លារ | |
| | អាករបន្ថែម | ០,០២០០ ដុល្លារ | | ០,០៤០០ ដុល្លារ | |
| | អាករពិសេស | ០,០៨៦៥ ដុល្លារ | | ០,០២៩៦ ដុល្លារ | |
| ៣ | **PREMIUM** | | ០,២០ ដុល្លារ | | ០,២៣ ដុល្លារ |
| ៤ | អាករលើតម្លៃបន្ថែម (១០% នៃ ១+២+៣) | | ០,០៦៧៦ ដុល្លារ | | ០,០៦១៥ ដុល្លារ |
| ៥ | ថ្លៃលក់រាយ/លីត្រ (គិតជាដុល្លារ) | | ០,៧៨៤០ ដុល្លារ | | ០,៦៧៦២ ដុល្លារ |
| ៦ | ថ្លៃលក់រាយ/លីត្រ (គិតជារៀល) | | ៣.១៧២ រៀល | | ២.៧៣៧ រៀល |
| ៧ | តម្លៃដែលត្រូវដាក់លក់រាយ/លីត្រ (គិតជាដុល្លារ) | | ០,៧៤ ដុល្លារ | | ០,៦៨ ដុល្លារ |
| ៨ | តម្លៃដែលត្រូវដាក់លក់រាយ/លីត្រ (គិតជារៀល) | | ៣.០០០ រៀល | | ២.៧៥០ រៀល |

សម្គាល់៖ អាត្រាប្តូរប្រាក់ផ្លូវការ ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២០ ដែលស្មើនឹង៤.០៤៨រៀល/ដុល្លារអាមេរិក

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

## តារាងថ្លៃលក់រាយប្រេងឥន្ធនៈនៅលើទីផ្សារអន្តរជាតិ

| ថ្ងៃខែឆ្នាំ | ប្រេងសាំងធម្មតា/ធុង EA 92 (USD/Barrel) | ប្រេងម៉ាស៊ូត/ធុង Gasoil (USD/Barrel) |
|---|---|---|
| ១៦ វិច្ឆិកា ២០២០ | ៤៥,២៥ | ៤៧,៧៤ |
| ១៧ វិច្ឆិកា ២០២០ | ៤៥,០៩ | ៤៧,៩០ |
| ១៨ វិច្ឆិកា ២០២០ | ៤៥,៣០ | ៤៨,៤៤ |
| ១៩ វិច្ឆិកា ២០២០ | ៤៥,២៦ | ៤៨,៦៧ |
| ២០ វិច្ឆិកា ២០២០ | ៤៥,៨០ | ៤៨,៨១ |
| ២៣ វិច្ឆិកា២០២០ | ៤៧,០១ | ៤៩,៩២ |
| ២៤ វិច្ឆិកា ២០២០ | ៤៧,៨៣ | ៥០,៨១ |
| ២៥ វិច្ឆិកា ២០២០ | ៤៩,៩៥ | ៥២,៥៦ |
| ២៦ វិច្ឆិកា ២០២០ | ៤៩,៥២ | ៥២,៣២ |
| ២៧ វិច្ឆិកា ២០២០ | ៤៩,៧៥ | ៥១,៩៧ |
| ៣០ វិច្ឆិកា ២០២០ | ៤៩,១១ | ៥១,៩៩ |
| **មធ្យមភាគ ១១ថ្ងៃ** | **៤៧,២៦០៩** | **៥០,១០២៧** |
| **មធ្យមភាគ (ដុល្លារ/លីត្រ)** | **០,២៩៧២** | **០,៣១៥១** |

**ក្រាហ្វិកបម្រែបម្រួលថ្លៃលក់រាយប្រេងឥន្ធនៈពីថ្ងៃទី១៦ ខែកញ្ញា ដល់ ០១ ខែធ្នូ ឆ្នាំ២០២០**




សូមបញ្ជាក់ថា ក្រសួងពាណិជ្ជកម្មមិនមែនជាអ្នកកំណត់ថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជាទេ គឺក្រសួងគ្រាន់តែស្រង់តម្លៃឡើង-ចុះ នៃប្រេងតាមទីផ្សារអន្តរជាតិ មកគណនាតាមប្រកាសដូចមានក្នុងឯកសារយោងខាងលើតែប៉ុណ្ណោះ ។

អាស្រ័យហេតុនេះ សូមសាធារណៈជនមេត្តាជ្រាបជាព័ត៌មាន និងសូមគ្រប់ស្ថានីយលក់រាយប្រេងឥន្ធនៈទាំងអស់ប្រតិបត្តិតាមការចាំបាច់។